ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ......០០២......អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ ក្នុងវិស័យបរធនបាលកិច្ច

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- ព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្ដីពីបរធបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការចុះបញ្ជីបរធនបាលកិច្ច
- យោងតាមការអនុម័តនៃសម័យប្រជុំរបស់ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីវិធាន បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាលនិងការពិន័យអន្តរការណ៍ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់ពី ន.ស.ធ. ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចដែលមានជាធរមាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ចំពោះការប្រព្រឹត្តល្មើសក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងច្បាប់ស្ដីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ៣.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីបរធនបាលកិច្ច÷

- **បុគ្គលប្រព្រឹត្តល្មើស** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់ ហើយអាចទទួលរងនូវការដាក់ទណ្ឌកម្មរដ្ឋបាល និង/ឬ ការពិន័យអន្តរការណ៍ពីមន្ត្រីអធិការកិច្ចបរធនបាលកិច្ច។
- **ទណ្ឌកម្មរដ្ឋបាល** សំដៅដល់វិធានការរដ្ឋបាល និងការផាកពិន័យ ដូចមានចែងក្នុងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ចជាធរមាន ដែលចេញដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះបុគ្គលប្រព្រឹត្តល្មើស។
- **ពិន័យអន្តរការណ៍** សំដៅដល់ការពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ចទៅលើបុគ្គលប្រព្រឹត្តល្មើសនឹងបញ្ញត្តិនៃច្បាប់ និងអនុក្រឹត្យជាធរមានក្នុងវិស័យបរធនបាលកិច្ច។
- **បុគ្គលរងទណ្ឌកម្ម** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច ហើយត្រូវទទួលរងទណ្ឌកម្មរដ្ឋបាល និង/ឬពិន័យអន្តរការណ៍ ពីមន្ត្រីអធិការកិច្ចបរធនបាលកិច្ច។



ដោយឡែកនូវមន្ត្រីរាជការ - https://t.me/oa_channel

## ជំពូកទី២
## គោលការណ៍ទូទៅនៃការដាក់ទណ្ឌកម្ម

**ប្រការ៤.-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មរដ្ឋបាល ពិន័យអន្តរការណ៍ និងកំណត់ការទូទាត់សំណង ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច។

**ប្រការ៥.-**

ការប្រព្រឹត្តល្មើសមួយត្រូវបានពិន័យអន្តរការណ៍តែម្តងគត់។ ការប្រព្រឹត្តល្មើសមួយគឺជាការប្រព្រឹត្តអំពើល្មើសណាមួយនៅក្នុងពេលវេលាមួយ និងក្នុងប្រភេទសកម្មភាពល្មើសតែមួយ ដោយបុគ្គលម្នាក់ឬច្រើននាក់រួមគ្នា ដោយការប្រព្រឹត្តល្មើសនោះត្រូវមានចែងដោយច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

ការប្រព្រឹត្តល្មើសដដែលៗច្រើនដង ឬមិនអនុវត្តតាមការចាត់វិធានការទណ្ឌកម្មរដ្ឋបាលពី **ន.ម.ធ.** ការប្រព្រឹត្តល្មើសនោះមិនត្រូវបានចាត់ទុកថាជាការប្រព្រឹត្តល្មើសមួយដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះឡើយ។

ការចាត់វិធានការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ អាចត្រូវបានធ្វើឡើងរួមគ្នា ឬដាច់ដោយឡែកពីគ្នាក្នុងពេលតែមួយ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច។

បុគ្គលច្រើនដែលបានប្រព្រឹត្តល្មើសរួមគ្នាត្រូវទទួលនូវការពិន័យអន្តរការណ៍ និង/ឬការដាក់ទណ្ឌកម្មរដ្ឋបាលរៀងៗខ្លួន។

**ប្រការ៦.-**

ការពិន័យអន្តរការណ៍ និង/ឬការដាក់ទណ្ឌកម្មរដ្ឋបាល មិនអាចអនុវត្តបាន ប្រសិន÷

១-គ្មានមូលដ្ឋានគតិយុត្តច្បាស់លាស់ និងមិនគោរពតាមបែបបទនិងនីតិវិធី ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច និងប្រកាសនេះ

២-បុគ្គលប្រព្រឹត្តល្មើសទទួលមរណភាព

៣-មានវិបល្លាសស្មារតីរបស់បុគ្គលប្រព្រឹត្តល្មើសជារូបវន្តបុគ្គល

៤-ចាត់វិធានការទណ្ឌកម្មជាន់គ្នាលើការប្រព្រឹត្តល្មើសតែមួយ ដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ។

**ប្រការ៧.-**

**ន.ម.ធ.** ត្រូវចេញសេចក្តីសម្រេចក្នុងការដាក់ទណ្ឌកម្មរដ្ឋបាល និង/ ឬពិន័យអន្តរការណ៍ដោយពិនិត្យទៅលើស្ថានទម្ងន់ និងស្ថានសម្រាលនៃការប្រព្រឹត្តល្មើស ដូចខាងក្រោម÷

ក-ត្រូវបានចាត់ចូលជាស្ថានសម្រាលនៃការប្រព្រឹត្តល្មើស នៅពេលដែលបុគ្គលប្រព្រឹត្តល្មើស÷

១-មានឆន្ទៈក្នុងការកែតម្រូវ និងជួសជុលការខូចខាត

២-បានរាយការណ៍អំពីការប្រព្រឹត្តល្មើស និងសារភាពអំពីកំហុស

៣-បានប្រព្រឹត្តល្មើសដោយសារមានការបង្ខិតបង្ខំ ឬគាបសង្កត់ពីបុគ្គលផ្សេងទៀត។

ធ

ខ-ត្រូវបានចាត់ចូលជាស្ថានទម្ងន់នៃការប្រព្រឹត្តល្មើស នៅពេលដែលបុគ្គលប្រព្រឹត្តល្មើស÷

១-ប្រព្រឹត្តល្មើសដោយមានការគិតទុកជាមុន

២-ប្រព្រឹត្តល្មើសច្រើនដង ឬបន្តបន្ទាប់

៣-បង្ខិតបង្ខំ ឬគំរាមកំហែងទៅលើបុគ្គលផ្សេងទៀតឱ្យប្រព្រឹត្តល្មើស

៤-ប្រព្រឹត្តល្មើសដោយរំលោភតួនាទី និងអំណាចរបស់បុគ្គលដទៃ

៥-ប្រព្រឹត្តល្មើសក្នុងខណៈពេលដែលបុគ្គលនោះកំពុងស្ថិតក្នុងដំណាក់កាលនៃការអនុវត្តវិធានការទណ្ឌកម្មរដ្ឋបាលរបស់ **ន.ម.ធ.**

៦-បន្តប្រព្រឹត្តល្មើសទោះបីជាបុគ្គលនោះត្រូវបានតម្រូវឱ្យបញ្ឈប់នូវអំពើល្មើសនោះ

៧-មានការលាក់កំបាំងការប្រព្រឹត្តល្មើស។

**ប្រការ៨.-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ច មានភារកិច្ចក្នុងការដាក់ទណ្ឌកម្មរដ្ឋបាល និងពិន័យអន្តរការណ៍ ដូចតទៅ÷

- ចេញសេចក្តីសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ឬពិន័យអន្តរការណ៍តាមប្រភេទនៃការប្រព្រឹត្តល្មើសស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- ចេញដីកាអមបង់ប្រាក់ ទទួលប្រាក់ និងចេញបង្កាន់ដៃបង់ប្រាក់ផាកពិន័យ ឬពិន័យអន្តរការណ៍ឱ្យបុគ្គលរងទណ្ឌកម្ម
- ផ្ញើដំណឹងជាលាយលក្ខណ៍អក្សរក្រើនរំលឹកចំពោះបុគ្គលប្រព្រឹត្តល្មើសឱ្យមកបង់ប្រាក់ផាកពិន័យ ឬពិន័យអន្តរការណ៍មិនឱ្យហួសកាលបរិច្ឆេទចុងក្រោយ
- កសាងសំណុំរឿងទៅតាមនីតិវិធីច្បាប់ជាធរមានទៅតុលាការមានសមត្ថកិច្ច ក្នុងករណីបុគ្គលប្រព្រឹត្តល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍។

## ជំពូកទី៣
## ការបង់ប្រាក់ផាកពិន័យ និងពិន័យអន្តរការណ៍

**ប្រការ៩.-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចអាចធ្វើការផាកពិន័យ ឬពិន័យអន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តល្មើសនូវចំនួនទឹកប្រាក់ដូចបានកំណត់នៅក្នុងច្បាប់ និង/ឬបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច។ ករណីបន្តប្រព្រឹត្តល្មើសដដែល មន្ត្រីអធិការកិច្ចបរធនបាលកិច្ចអាចផាកពិន័យនូវចំនួនទឹកប្រាក់ទ្វេដងនៃចំនួនទឹកប្រាក់ផាកពិន័យលើកមុន។ ករណីការប្រព្រឹត្តល្មើសនោះបង្កឱ្យមានការខូចខាតដល់សាធារណជន ឬអតិថិជន ឬភាគីណាមួយនៃបរធនបាលកិច្ច មន្ត្រីអធិការកិច្ចបរធនបាលកិច្ចអាចផាកពិន័យចំនួនទឹកប្រាក់ទ្វេដងនៃចំនួនដែលរងការខូចខាត។

Ug

**ប្រការ១០.-**

បុគ្គលរងទណ្ឌកម្មត្រូវបង់ប្រាក់ផាកពិន័យ ឬពិន័យអន្តរការណ៍ជូនមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចផាកពិន័យ ឬពិន័យអន្តរការណ៍ ឬតាមការកំណត់របស់ **ន.ម.ធ.**។

ក្នុងករណីបុគ្គលរងទណ្ឌកម្មយឺតយ៉ាវ ឬខកខានបង់ប្រាក់ផាកពិន័យ ឬយឺតយ៉ាវពិន័យអន្តរការណ៍តាមកាលកំណត់របស់ **ន.ម.ធ.** គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចផាកពិន័យ ឬពិន័យអន្តរការណ៍ នោះចំនួនទឹកប្រាក់ផាកពិន័យ ឬពិន័យអន្តរការណ៍ នឹងត្រូវបូកបន្ថែម ២ (ពីរ) ភាគរយ នៃទឹកប្រាក់ផាកពិន័យ ឬពិន័យអន្តរការណ៍ដើម។

ក្នុងករណីវិវាទរូសមិនព្រមបង់ប្រាក់ផាកពិន័យ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចផាកពិន័យ និងមិនបានដាក់ពាក្យបណ្តឹងតវ៉ានៅក្នុងរយៈពេលកំណត់ នោះមន្ត្រីអធិការកិច្ចបរធនបាលកិច្ច អាចដាក់ទណ្ឌកម្មរដ្ឋបាលធ្ងន់ជាងនេះ។

ក្នុងករណីវិវាទរូសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចពិន័យអន្តរការណ៍ និងមិនបានដាក់ពាក្យបណ្តឹងតវ៉ានៅក្នុងរយៈពេលកំណត់ នោះមន្ត្រីអធិការកិច្ចបរធនបាលកិច្ចត្រូវកសាងសំណុំឯកសារបញ្ជូនទៅតុលាការ ដើម្បីចាត់ការទៅតាមនីតិវិធីច្បាប់។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរលត់បណ្តឹងអាជ្ញា។

## ជំពូកទី៤
## វិធានការរដ្ឋបាល

**ប្រការ១១.-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចអាចចាត់វិធានការរដ្ឋបាលចំពោះបុគ្គលប្រព្រឹត្តល្មើសនូវវិធានការណាមួយដូចមានចែងក្នុងប្រការ១២ នៃប្រកាសនេះ និងស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច។

ករណីបន្តប្រព្រឹត្តល្មើសដដែល មន្ត្រីអធិការកិច្ចបរធនបាលកិច្ចអាចដាក់ទណ្ឌកម្មរដ្ឋបាលធ្ងន់ណាមួយបន្ថែមទៀត។

**ប្រការ១២.-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចអាចចាត់វិធានការរដ្ឋបាល ចំពោះបុគ្គលដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់ ដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងវិធានការរដ្ឋបាលណាមួយ ដូចខាងក្រោម÷

- ការព្រមាន
- ការដឹកនាំកែតម្រង់
- ការដាក់កំហិតលើអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់

- ការដាក់កំហិតលើការចាត់ចែង គ្រប់គ្រង និង/ឬការថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច
- ការព្យួរអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់
- ការព្យួរ ឬបណ្តេញចេញពីមុខតំណែងអភិបាល បុគ្គលិកជាន់ខ្ពស់ និង/ឬបុគ្គលប្រព្រឹត្តល្មើស
- ការដកហូតអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់។

**ប្រការ១៣.-**

វិធានការរដ្ឋបាលអាចធ្វើឡើងដោយកំណត់រយៈពេលជាក់លាក់ណាមួយ ឬមិនកំណត់រយៈពេល អាស្រ័យតាមចរិតលក្ខណៈនៃវិធានការរដ្ឋបាលនីមួយៗ។

## ជំពូកទី៥
## ការចាប់ផ្តើមនីតិវិធីដាក់ទណ្ឌកម្មរដ្ឋបាល និងពិន័យអន្តរការណ៍

**ប្រការ១៤.-**

មុនពេលចាត់វិធានការទណ្ឌកម្មណាមួយ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺដោយផ្ទាល់មាត់ឬលាយលក្ខណ៍អក្សរ ក្នុងរយៈពេលកំណត់ជាក់លាក់។ ការស្រាយបំភ្លឺនេះគឺជាមូលដ្ឋានគ្រឹះនៃការពិចារណាទៅលើស្ថានទម្ងន់ និងស្ថានសម្រាលទោស តាមឆន្ទានុសិទ្ធិរបស់ **ន.ម.ឧ.** ដោយអនុលោមតាមប្រការ៧ នៃប្រកាសនេះ និងតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១៥.-**

បន្ទាប់ពីបានស្តាប់ការឆ្លើយបំភ្លឺរបស់បុគ្គលប្រព្រឹត្តល្មើស ឬអ្នកតំណាងរបស់បុគ្គលនេះ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចអាចសម្រេច ដូចខាងក្រោម÷

១- មិនចាត់វិធានការដាក់ទណ្ឌកម្មណាមួយ ក្នុងករណីពិនិត្យឃើញថាបុគ្គលស្ថិតក្នុងលក្ខខណ្ឌដូចមានចែងក្នុងប្រការ៦ នៃប្រកាសនេះ។ ក្នុងករណី **ន.ម.ឧ.** សម្រេចមិនចាត់វិធានការដាក់ទណ្ឌកម្ម មន្ត្រីអធិការកិច្ចបរធនបាលកិច្ចត្រូវអនុញ្ញាតឱ្យបិទសំណុំរឿង ដើម្បីតម្កល់សំណុំរឿងទុកជាសាវតារបស់បុគ្គលនោះ។

២- អាចចាត់វិធានការដាក់ទណ្ឌកម្ម ក្រៅពីមូលហេតុដូចមានចែងក្នុងចំណុច១ នៃប្រការនេះ ដោយចេញសេចក្តីសម្រេច ឬលិខិតជាលាយលក្ខណ៍អក្សរ និងតាមទម្រង់កំណត់របស់ **ន.ម.ឧ.**។

## ជំពូកទី៦
## អានុភាពនៃវិធានការទណ្ឌកម្ម

**ប្រការ១៦.-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចអាចបញ្ជូនសេចក្តីសម្រេច ឬលិខិតជូនដំណឹង និង/ឬឯកសារពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្មរដ្ឋបាល និង/ឬការពិន័យអន្តរការណ៍ទៅគេហដ្ឋាន ឬទីស្នាក់ការរបស់បុគ្គលទទួលរងទណ្ឌកម្មតាមលិខិតអនុសិដ្ឋ។

ក្នុងករណីដែលបុគ្គលទទួលរងទណ្ឌកម្មបដិសេធមិនព្រមទទួលសេចក្តីសម្រេចឬលិខិតជូនដំណឹង និង/ឬ ឯកសារពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្មរដ្ឋបាល និង/ឬការពិន័យអន្តរការណ៍ ឬមិនមានបុគ្គលទទួល មន្ត្រីអធិការកិច្ច បរធនបាលកិច្ចអាចបិតសេចក្តីជូនដំណឹងអំពីការដាក់ទណ្ឌកម្មរដ្ឋបាល និង/ឬការពិន័យអន្តរការណ៍នៅគេហដ្ឋាន ទីស្នាក់ការរបស់បុគ្គលទទួលរងទណ្ឌកម្ម ឬសាលាឃុំ/សង្កាត់ ឬផ្សព្វផ្សាយជាសាធារណៈ។ បន្ទាប់ពីបានបិតផ្សាយ ឬផ្សព្វផ្សាយរួច ឯកសារទាំងនោះត្រូវចាត់ទុកថាបានទទួលជាផ្លូវការដោយបុគ្គលទទួលរងទណ្ឌកម្មរដ្ឋបាល និង/ឬ ការពិន័យអន្តរការណ៍។

**ប្រការ១៧.-**

បុគ្គលទទួលរងទណ្ឌកម្មមិនសុខចិត្តនឹងវិធានការណាមួយ អាចប្តឹងតវ៉ានឹងវិធានការនោះមក **ន.ប.ធ.** ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលវិធានការ។

ប្រសិនបុគ្គលទទួលរងទណ្ឌកម្ម មិនសុខចិត្តនឹងវិធានការរបស់ **ន.ប.ធ.** អាចប្តឹងតវ៉ាទៅតុលាការ ក្នុង រយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលវិធានការនោះ។

**ប្រការ១៨.-**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រលើការផាកពិន័យ ឬពិន័យ-អន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តល្មើស ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបោះពុម្ព និងបើកផ្តល់ដោយ **ន.ប.ធ.** តាមទម្រង់កំណត់ដោយ **ន.ប.ធ.**។

## ជំពូកទី៧

## ទណ្ឌកម្មរដ្ឋបាលបន្ថែមរបស់ ន.ប.ធ.

**ប្រការ១៩.-**

**ន.ប.ធ.** អាចចាត់វិធានការទណ្ឌកម្មបន្ថែមទៅលើវិធានការទណ្ឌកម្មផ្សេងទៀត ដែលមានចែងក្នុងច្បាប់ បទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ច និងប្រកាសនេះ ក្នុងករណីរកឃើញថាបុគ្គលដែលស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់ **ន.ប.ធ.** បានប្រព្រឹត្តល្មើសនឹងច្បាប់និងបទប្បញ្ញត្តិដទៃទៀត ដូចខាងក្រោម÷

- ចេញបទបញ្ជាឱ្យបុគ្គលធ្វើការទូទាត់សំណង ស្របតាមប្រកាសនេះ និងបទប្បញ្ញត្តិដទៃទៀត
- ស្នើសុំទៅតុលាការមានសមត្ថកិច្ច ដើម្បីចេញដីកាតម្រូវឱ្យបុគ្គលអនុវត្តតាមច្បាប់ និងឱ្យជួសជុល សំណងព្យសនកម្មតាមការកំណត់របស់តុលាការ
- ព្យួរជាបណ្តោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយក សមាជិកគណៈគ្រប់គ្រង ឬបុគ្គលិក ជាន់ខ្ពស់របស់នីតិបុគ្គលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់ពី **ន.ប.ធ.**

ប៉

- ជ្រើសរើស និងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើល សកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់បុគ្គលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់ពី **ន.ម.ធ.** និង
- ដាក់កំហិត ឬបញ្ឈប់សកម្មភាពជាក់លាក់ ឬទូទៅដែលធ្វើឡើងដោយបុគ្គលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់ពី **ន.ម.ធ.** ទោះបីជាសកម្មភាពទាំងនោះត្រូវបានធ្វើឡើងស្រប ឬមិនស្របតាមលក្ខខណ្ឌអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់ ក៏ដោយ។

ក្នុងករណីដែល **ន.ម.ធ.** រកឃើញថា បុគ្គលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់ពី **ន.ម.ធ.** ស្ថិតក្នុងស្ថានភាពអសាធនីយ៍ ឬមានបញ្ហាផ្នែកហិរញ្ញវត្ថុ **ន.ម.ធ.** អាចប្រើប្រាស់អំណាចរបស់ខ្លួន ដើម្បីតែងតាំង ឬស្នើសុំទៅតុលាការដើម្បីតែងតាំងបុគ្គលដែលមានសមត្ថភាពសមស្របឱ្យធ្វើជាអភិបាលបណ្តោះអាសន្ន ដើម្បីគ្រប់គ្រង និងរៀបចំឡើងវិញ ឬជម្រះបញ្ជីបុគ្គលនោះ ស្របតាមច្បាប់ស្តីពីក្ស័យធននៃព្រះរាជាណាចក្រកម្ពុជា ឬបទប្បញ្ញត្តិផ្សេងទៀត។

## ជំពូកទី៨
## ការអនុវត្តសេចក្តីសម្រេច

**ប្រការ២០.-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ច អាចផ្សព្វផ្សាយជាសាធារណៈ ឬជូនដំណឹងទៅបុគ្គលណាមួយនូវសេចក្តីសម្រេច ឬលិខិតដាក់ទណ្ឌកម្មរដ្ឋបាល ឬពិន័យអន្តរការណ៍។

**ប្រការ២១.-**

សំណុំរឿងដែលត្រូវបានសម្រេចឱ្យបិទ ត្រូវរក្សាទុកយ៉ាងតិចក្នុងរយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទបិទសំណុំរឿង។

**ប្រការ២២.-**

ករណីដែលបុគ្គលទទួលរងទណ្ឌកម្មមិនអនុវត្តតាមការចាត់វិធានការទណ្ឌកម្មរបស់ **ន.ម.ធ.** ត្រូវទទួលនូវស្ថានទម្ងន់ទោសនៃការចាត់វិធានការទណ្ឌកម្មតាមប្រកាសនេះ។

ក្នុងករណីដែលបុគ្គលប្រព្រឹត្តល្មើសមិនបង់ប្រាក់ផាកពិន័យតាមសេចក្តីសម្រេចរបស់ **ន.ម.ធ.** ទេ ប្រាក់ផាកពិន័យនោះត្រូវក្លាយជាបំណុល ដែលមាន **ន.ម.ធ.** ជាម្ចាស់បំណុល។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**ប្រការ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។



ឞ

**ប្រការ២៤.-**

អគ្គនាយកនៃ **ន.ប.ធ.** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច គ្រប់ប្រធាននាយកដ្ឋាន-អង្គភាពចំណុះឱ្យ **ន.ប.ធ.** បុគ្គលដែលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់ពី **ន.ប.ធ.** និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ.
- ដូចប្រការ ២៤

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ